● តំបន់តាទុង /ល័នសឹកហ្វាងហ័រ-រឿងនិទាមុនចូលគេងរបស់ម្ដាយ

ខ្ញុំនៅចាំបានកាលពីតូចៗនូវពេលមុនចូលគេង

ខ្ញុំចូលចិត្តនៅក្បែរដើមទ្រូងម៉ាក់ខ្ញុំណាស់

បានស្ដាប់សម្លេងម៉ាក់ស្រទន់ដ៏ផ្អែមពិរោះ និយាយរឿងនិទានៅលើគ្រែ

ខ្ញុំក៏ស្ងាត់ស្ងៀមគេងលក់ដល់សុបន្តិ។

ប្រសិនជាមានដើមឈើដ៏ធំខ្ពស់មួយបានដុះផ្លែពេញមេក ជារៀងរាល់ថ្ងៃ

នឹងមានក្មេងកុមារជាច្រើនសប្បាយរីករាយមកប្រលែងលេងកំសាន្តនៅក្រោមម្លប

ដើមឈើនេះ ប្រលែងលេងហាត់ហើយ

គឺអង្គុយនៅក្រោមម្លុបដើមឈើនឹងសំរាកសិន

នូវពេលឃ្លានហើយក៏ឡើងទៅបេះផ្លែឈើមកញុំា។

ថ្ងៃមួយមានកុមារម្នាក់ដើរកាត់ក្បែរដើមឈើនោះ ស្រាប់តែដើមឈើនិយាយថា:

កូនក្មេងអើយ! មកៗប្រញាប់មកលេងជិះតូងនឹងឡើងដើមឈើមក!

កូនក្មេងឆ្លើយតបថា៖ ខ្ញុំមិនចង់លេងទេ!

ខ្ញុំចង់មានលុយដើម្បីយកបើកហាងលក់ដូរវិញ។

ដើមឈើនិយាយថា៖ កូនក្មេងអើយ! យើងអត់មានលុយឲ្យកូនទេ

ប៉ុន្តែយើងមានផ្លែឈើ

កូនឯងអាចបេះផ្លែឈើទាំងនេះយកទៅលក់យកលុយបាន។

កូនក្មេងនោះឡើងដើមឈើភ្លៀម៖ ពិតជាល្អណាស់!

ខ្ញុំនឹងបេះផ្លែឈើនេះទាំងអស់យកទៅលក់ហើយណា!

ដើមឈើនិយាយ៖ បើសិនកូនឯងបានសំរេចភារិកច្ចហើយ

ត្រូវមកលេងយើងផង យើងនឹកឯងណាស់ណា!

ជាយូរយារកន្លងផុតមក

ដើមឈើសម្លឹងមើលឃើញក្មេងម្នាក់ដូចធ្លាប់ស្គាល់ធ្វើដំណើរពីចម្ងាយមក

ដើមឈើមានភាពរំភើបរំជួយស្រែកប្រាប់ថា៖

កូនសំលាញ់កូនវិលប្រឡប់មកវិញហើយ មកមកមក។

មកឡើងលើខ្នងយើងមក!

ក្មេងឆ្លើយថា: ខ្ញុំមិនចង់ឡើងដើមឈើនឹងទេ! ខ្ញុំចង់សង់ផ្ទះមួយសំរាប់ខ្លួនឯង។

ដើមឈើស្តាប់ហើយមានភាពអស់សង្ឃឹមបន្តិច ក៏និយាយថា:

អឺម»»ចឹងក៏បាន! ឯងយកដើមខ្នងយើងទៅសាងសង់ចុះ!

កូនក្មេងបានស្តាប់ហើយ: អោ! ដើមខ្នងយើងធំៗហើយមាំៗទៀត

ចឹងខ្ញុំមិនខ្លាចចិត្តហើយណាខ្ញុំយកហើយ។

ដើមឈើនិយាយ: កូនអើយ! បើសិនកូនឯងសាងសង់ផ្ទះរួចហើយ

ត្រូវមកលេងយើងផង យើងនឹកឯងណាស់ណា!

រដូវផ្ការីក រដូវក្តៅ រដូវធ្លាក់ខ្យល់ រដូវរងារ ផ្លាស់ប្តូរបួនរដូវ

១០ឆ្នាំជាងកន្លងផុតទៅ។

ដើមឈើបានមើលឃើញ មានមនុស្សជំទង់ម្នាក់ដើរសំដៅមកកាន់គាត់

គឺជាក្មេងដែលគាត់ទន្ទឹមរង់ចាំនឹកទាំងយប់ទាំងថ្ងៃ! ដើមឈើក៏សួរថា:

កូនអើយ! កូនវិលមករស់នៅក្បែរយើងវិញហើយមែនឬទេ?

ក្មេងឆ្លើយថា៖ មិនមែនចឹងទេ ខ្ញុំចង់បានទូកមួយ

ប៉ុន្តែខ្ញុំអត់មានឈើមាំៗយកធ្វើទូកទេ។

ដើមឈើនិយាយ៖

កូនកាប់ដើមឈើយើងដែលមាំជាងគេបង្អស់យកទៅធ្វើទូកឯងចុះ!

ក្មេងវ័យជំទង់ស្តាប់ហើយក៏ឆ្លើយថា៖ មេកឈើយើងមាំល្អណាស់

សាសមខ្ញុំយកមកធ្វើធ្វើទូកណាស់ តែប៉ុណ្ណោះខ្ញុំអាចបំពេញក្តីស្រមៃខ្ញុំហើយ!

ដើមឈើបានគិតថាគាត់មិនមែនជាដើមឈើដ៏ធំទៀតហើយ

នៅសេសសល់តែ១មែកតូចខ្យល់អាចភ្លុំរឡំបាក់នៅថ្ងៃណាមួយមិនខាន

ប៉ុន្តែនឹងមានថ្ងៃណាមួយក្មេងនឹងនៅត្រូវការខ្ញុំទៀត

ខ្ញុំត្រូវតែរងចាំបន្តិចទៀតសិន។

មានថ្ងៃមួយដើមឈើឈរនៅលើស្មៅយ៉ាងស្ងាត់ស្ងៀម

មានភាពថាអផ្សុកណាស់សម្លឹងមើលទៅតាមដងផ្លូវ ក៏ឈរនឹកគិតដល់

「ក្មេងដែលដើមឈើនឹករលឹកទាំងយប់ទាំងថ្ងៃ」។

ដើមឈើបានហូរទឹកភ្នែករួចវាថារថា: កូនអើយ!

យើងទន្ទឹមរងចាំកូនវិលវិញហើយ លើកនេះតើកូនចង់បានអ្វីទៀត?

ប៉ុន្តែយើងលែងមានសម្ថភាពអ្វីអោយកូនទៀតហើយ កូនអើយ!

កុមារវ័យជំទង់ដែលមានអាយុច្រើនកាន់តែចាស់ទៅ

ហើយភាពធុញទ្រាន់និងហត់នឿយ

បានស្រក់ទឹកភ្នែកមកហើយបាននិយាយថា:

ខ្ញុំមានការធុញទ្រាន់ដូច្នេះខ្ញុំចង់កន្លែងដ៏ស្ងាត់មួយដើម្បីសម្រាក

ខ្ញុំអាចអង្គុយក្បែរអ្នកឬទេ?

ដើមឈើបាននិយាយថា: កូនអើយ យើងនៅទីនេះ!

កូនឯងអាចអង្គុយនៅទីនេះជារៀងរហូតណា ទៅថ្ងៃមុខកូនកុំព្រួយបារម្ភអី។

កូនក្មេងបានឆ្លើតថា: ដើមឈើអើយ

ដើមឈើឯងបានផ្តល់ក្តីស្រលាញ់កក់ក្តៅអោយខ្ញុំច្រើនណាស់

ពេលនេះខ្ញុំយល់ហើយ។

ពិតណាស់

ដើមឈើដែលមានក្តីធម៌មេតាបានផ្តល់ក្តីស្រលាញ់កក់ក្តៅនិងការរង់ចាំ

ហាក់ដូចជាសេចក្តីស្រឡាញ់របស់ម្តាយចំពោះកូនចំពោះពួកគេដោយមិនចង់បា

នអ្វីពីកូនៗវិញឡើយ  នៅពេលដែលយើងអស់ក្តីសង្ឃឹមឬយើងយំ

គាត់តែងតែចង់ហុចដៃផ្តល់មេតាដល់ក្មេងនោះ

ដូច្នេះជាដៃរបស់ម្តាយទាំង២ឱបក្បាលគាត់ចឹង

ខ្ញុំបានឮម្តាយរបស់ខ្ញុំនិយាយថា: កូនអើយ

កុំភ័យខ្លាចអ្វីនៅទីនេះជាមួយម៉ាក់យើងកំដរកូនណា។